ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សភាជំនុំជម្រះរដ្ឋប្បវេណី
សំណុំរឿងរដ្ឋប្បវេណី
លេខ ៨៥ តាងនាមប្រជារាស្ត្រខ្មែរ
ចុះថ្ងៃទី២០ខែមិនាឆ្នាំ១៩៩៧
សាលដីកា តុលាការកំពូល
លេខ ២១៥
ចុះថ្ងៃទី១៣ខែតុលាឆ្នាំ១៩៩៨ បានបើកសវនាការ ជំនុំជម្រះ ជាសាធារណៈ
នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៨ ដែលមានសមាសភាពដូចតទៅ :

១ - ឯកឧត្តម ឌិត មុន្ទី ប្រធាន
២ - លោក ខឹម ពុន ចៅក្រម
៣ - លោក តេវ ឆួន ចៅក្រម
៤ - លោក ព្រុំ ឌឹម ចៅក្រមរបាយការណ៍
៥ - លោក ជីវ កេង ចៅក្រម

ក្រឡាបញ្ជី
លោក ទេព វុធ

តំណាងអយ្យការ
លោក សាយ សាវី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះ លើបណ្តឹងសាទុក្ខពី សាលដីការដ្ឋប្បវេណីលេខ ៤៤៥ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៩៦ នៃ សំណុំរឿងរដ្ឋប្បវេណីលេខ ៣២៧ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ១៩៩៥ របស់ សាលាឧទ្ធរណ៍ ។

រវាងភាគីបណ្តឹងសាទុក្ខឈ្មោះ ប៊ី សេង អាយុ ៤៩ឆ្នាំ សញ្ជាតិកម្ពុជា របររកស៊ី ធ្វើស្រែ ទីលំនៅសព្វថ្ងៃ ភូមិចំការលើខាង III ឃុំចំការលើខាង ស្រុកស្វាយចេក ខេត្តបាត់ដំបង ឪពុកឈ្មោះ ពុក ប៊ី " ស " ម្តាយឈ្មោះ ទេវ៉ា សាង " ស " ។

និង ចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ លោក សុវណ្ណារ៉ា អាយុ២៨ឆ្នាំ សញ្ជាតិកម្ពុជា របររកស៊ី ធ្វើការ ទីលំនៅសព្វថ្ងៃ ភូមិចំការលើខាង III ឃុំចំការលើខាង ស្រុកស្វាយចេក ខេត្តបាត់ដំបង ឪពុកឈ្មោះ លោក ប៊ុនលី " ស " ម្តាយឈ្មោះ លោក គឹម " រ ។"

កម្មវត្ថុបណ្តឹង : ប្តឹងសុំសិទ្ធិគ្រប់គ្រងដី

តាមពាក្យបណ្តឹងសាទុក្ខលេខ ៣២៧ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ១៩៩៦ របស់អ្នកស្រី ប៊ី សេង បានប្តឹងមិនសុខចិត្តនឹងសាលដីកា របស់ សាលាឧទ្ធរណ៍ គ្រប់ចំណុច នៃ សេចក្តីសម្រេចទាំងមូល ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ៨៥ ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ១៩៩៧ របស់ តុលាការកំពូល ។

តាមពាក្យបណ្តឹងរបស់ឈ្មោះ លោក សុវណ្ណារ៉ា ចុះថ្ងៃទី ២៤-៧-៩៥ ប្តឹងសុំសិទ្ធិ

គ្រប់គ្រងដីទំហំ ២៥ម គុណ ៥០ម ពីឈ្មោះ ហ៊ី សេង ដោយយល់ថាខ្លួនជាកូនថា ដីទំនាស់នេះ នៅឆ្នាំ១៩៨៣ ឪពុកពិការបានប្រគល់អោយខ្លួនកាន់កាប់ និង គ្រប់គ្រងរហូតមក ប្រាប់ថែ ក្នុងពេលថ្មីៗនេះ ឈ្មោះ ហ៊ី សេង ធ្វើរបងព័ទ្ធយកដីទំនាស់នេះទៅគ្រប់គ្រង ។

បានឃើញ សាលក្រមឧទ្ធរណ៍លេខ ២៨១ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៨៥ របស់ តុលាការ ខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១ - ទទួលពាក្យបណ្តឹងចុះថ្ងៃទី ២៤ - ០៣ - ៨៥ របស់ឈ្មោះនាង សោម សុវណ្ណារ៉ា ប្តឹងសុំសិទ្ធិគ្រប់គ្រងដីពីឈ្មោះនាង ហ៊ី សេង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - ក ទទួលយកវិរុទ្ធពាក្យ នាទេសនាការ របស់អ្នកទាមទារសិទ្ធិគ្រប់គ្រងដីជាកម្មសិទ្ធិ ទុកជាត្រឹមត្រូវតាមគតិច្បាប់ ។

- ១ បដិសេធចោលវិរុទ្ធពាក្យរបស់ចុងចម្លើយសុំអោយទុកទេរីផ្ទះដោយផ្ទុយនឹង គតិច្បាប់ ។

៣ - ប្រគល់ជាកម្មសិទ្ធិអោយដល់ ៖

ក - ឈ្មោះ សោម សុវណ្ណារ៉ា ជាដើមចោទនូវដីទំហំ AA'C'B' គឺ AA' : ២៦ម A'C' : ១៤ម , C'B' : ២៥,៥ម , AB' : ១៦ម

ខ - ឈ្មោះ ហ៊ី សេង ជាចុងចម្លើយនូវដីទំហំ A'IHGFEDCBB'C' ស្ថិតនៅភូមិ ចំការសំរោង ឃុំចំការសំរោង ស្រុកក្តាយឡៅ ខេត្តបាត់ដំបង គិតចាប់ពីថ្ងៃដែល សាលក្រមនេះចូលជាស្ថាពរ តាមគំនូសប្លង់បង្ហាញទីតាំងដីទំនាស់ចុះថ្ងៃទី ២១ - ០៥ - ៨៥ របស់ការិយាល័យសុរិយោដីខេត្តបាត់ដំបង ។

៤ - អោយឈ្មោះ ហ៊ី សេង ជាចុងចម្លើយរុះរើរបងហ៊ុំព័ទ្ធលើដីជាកម្មសិទ្ធិរបស់ សោម សុវណ្ណារ៉ា ជាដើមចោទ គិតចាប់តាំងពីថ្ងៃដែល សាលក្រមនេះចូលជាស្ថាពរ ។

តាមអនុក្រឹត្យ លេខ ២៥ អនក្រ ចុះថ្ងៃទី ២០ មេសា ១៩៨៩ ។

តាមមាត្រា ៣ , ១២ , ២២ , ៦២ , ៦៦ , ៦៧ , ៦៨ , ៦៩ , ៧០ , ៧២ , ៧៤ , ៧៩ , ៨០ និង មាត្រា ៩៩ នៃច្បាប់ភូមិបាល ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១០០ក្រ ចុះថ្ងៃទី ១៣ តុលា ១៩៩២ ។

៥ - អោយដើមចោទ និង ចុងចម្លើយ រួមគ្នាបង់ប្រាក់ប្រដាប់ក្តីចំនួន ៧.០០០រ គឺ

- ពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹងចំនួន ១.៨០០រ០០
- រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រ០០
- រង្វាន់ប្រគល់ដីការកោះ និង ចំណាយក្នុងកិច្ចស៊ើបអង្កេតចំនួន ៥.០០០រ០០

សរុប ៧.០០០រ០០ ។

ប្រាក់នេះត្រូវកាត់យកពីប្រាក់ ៧.០០០រ០០ ដែលដើមចោទបានបង់រួចហើយ កាលដើមប្តឹងដំបូង អោយចុងចម្លើយសងប្រាក់ ៣.៥០០រ០០ ទៅដើមចោទវិញ និង អោយរួមគ្នាបង់ពន្ធមហាមាត្រចំនួន ១០.០០០រ០០ បន្ថែមទៀត ។ ប្រាក់នេះត្រូវដាក់ចូលថវិការដ្ឋ ៨០ ភាគរយ និង ២០ ភាគរយដាក់ចូលក្នុងហិបប្រាក់ក្រឡាបញ្ជីទូទាំងប្រទេស ។

តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តីដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៧ ក្រ

ចុះថ្ងៃទី ០៨ កុម្ភៈ ១៩៨៧ ។

៦ - សាលក្រមនេះ ជំនុំជំរះ និង ប្រកាសជា សាធារណៈចំពោះមុខក្ដី ។ បើកផ្លូវប្ដឹងឧទ្ធរណ៍ ២ខែ គិតពីថ្ងៃប្រកាស សាលក្រម តទៅ ។

បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ១៥០ ចុះថ្ងៃទី ២១-១២-៨៥ របស់ឈ្មោះ ហ៊ី សេង ប្ដឹងមិនសុខចិត្តនឹងសាលដីកា របស់ សាលាឧទ្ធរណ៍ ត្រង់ចំណុចទី២ សេចក្ដីសំរេចខាងចូល ធ្វើទៀង ក្នុងកំណត់ច្បាប់ ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ ៤៤៥ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៨៥ របស់ សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃ សេចក្ដីសំរេចដូចតទៅ ៖

១ - ទទួលពាក្យបណ្ដឹង របស់ឈ្មោះ ហ៊ី សេង ចុះថ្ងៃទី ២១-១២-១៩៨៥ ទុកជាត្រឹមត្រូវ តាមទំរង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់ ។

២ - តម្កល់ សាលក្រមលេខ ២៥១ ចុះថ្ងៃទី ១៦-១២-១៩៨៥ របស់ តុលាការ ខេត្តបាត់ដំបង ទុកជាបានការពេញទាំងមូល ។

៣ - ការអោយប្រាក់ប្រដាប់ក្ដីជាន់ សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛០០ ដែលដើមបណ្ដឹងឧទ្ធរណ៍ បានបង់រួចហើយ គឺ ពន្ធចុះបញ្ជីក្ដី និង ពន្ធប្ដឹង ៥.៥៥០៛០០ តម្លៃក្រដាសបញ្ជី ការពិនិត្យប្រាក់ ៤៥០៛០០ ចំណាយក្នុងកិច្ចប្រគល់ដីកាពោះ ៥.០០០៛០០ និង ចំណាយលើអាហារតុលាការ ២.០០០៛០០ សរុប ១៣.០០០៛០០ ។

៤ - សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខ ហ៊ី សេង កំបាំងមុខឈ្មោះ គោម សុវណ្ណារ៉ា បើកផ្លូវប្ដឹងទាស់ និង សាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្ដឹងសាទុក្ខលេខ ៣៦៧ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ១៩៨៦ របស់ឈ្មោះ ហ៊ី សេង ធ្វើទៀងក្នុងកំណត់ច្បាប់ ។

បានឃើញសារណាចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៨៧ របស់អ្នកស្រី ហ៊ី សេង

បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
បានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា ៖

បណ្ដឹងសាទុក្ខរបស់ចុងចម្លើយធ្វើនៅក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះមកពិនិត្យពិចារណា ។

សាលដីការដ្ឋប្បវេណីលេខ ៤៤៥ ចុះថ្ងៃទី ០៤-១១-៨៥ របស់ សាលាឧទ្ធរណ៍ ដែលបានសំរេចមានការខុសឆ្គង ខាងទំរង់ ទាំងគតិច្បាប់ ។

អ្នកស្រី ហ៊ី សេង បានថ្លែងថា ព្រោះការកាត់សេចក្ដីមកនេះមិនត្រឹមត្រូវ ដោយអាងហេតុថា ដីនេះខ្លួនបានកាន់កាប់តាំងពីឆ្នាំ១៩៧៩ មកម្ល៉េះ ផ្ទះនេះសព្វថ្ងៃគ្មានអ្នកណានៅទេ ហើយមកគេសុំអោយ ឯកឧត្តមទេសាភិបាលជួយដោះស្រាយអោយខ្លួនតាមគតិយុត្តិធម៌ផង ។

- ក្រោយពីបានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់ចម្លើយដោះសារ របស់អ្នកស្រី ហ៊ី សេង

៧/.

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ៣២៧ ចុះថ្ងៃទី ០៤-១២-៩៦ របស់ អ្នកស្រី ពុំ ហេង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមក ជំនុំជំរះ បានតាមមាត្រា ១៤ នៃច្បាប់ស្ដីពី ការចាត់តាំង និង សកម្មភាព របស់សាលាជំរះក្ដី ។

- យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ឪពុកដើមចោទពិតជា បានសុំដីទំនាស់ពីចុងចម្លើយស្នាក់នៅបណ្ដោះអាសន្នតាមរយៈប្រធានក្រុមទី ២៤ និង ២៥ ដោយ មានការឯកភាពពីចុងចម្លើយកាលពីឆ្នាំ ១៩៨៥ ដើម្បីរស់នៅត្រឹមមួយអាយុខ្លួនប៉ុណ្ណោះ ។

- យល់ឃើញថា ការដែលដើមចោទប្ដឹងទាមទារយកដីទំនាស់របស់ចុងចម្លើយ ដោយយកអំណះអំណាងថា ដីទំនាស់ជាដីដែលរដ្ឋអំណាចមូលដ្ឋានបានចែកអោយខ្លួន ដូចមានបង្កាន់ដៃ ទទួលពាក្យលេខ ៣៣៣ ចុះថ្ងៃទី ១៥-០១-៩២ នោះជាការពុំត្រឹមត្រូវទេ ពីព្រោះ ដីទំនាស់ត្រូវបានចុងចម្លើយចូលមកកាន់កាប់ គ្រប់គ្រង និង ថែរក្សា អាស្រ័យផលតាំងពី ឆ្នាំ១៩៧៩ រហូតមកមាន រដ្ឋអំណាចមូលដ្ឋានទទួលស្គាល់ត្រឹមត្រូវ ។ រីឯឪពុកដើមចោទ ដែលចូលមកសុំចុងចម្លើយស្នាក់នៅតាមរយៈប្រធានក្រុមនោះក្នុងលក្ខណៈជាបណ្ដោះអាសន្ន ទំរាំខ្លួនស្លាប់តែប៉ុណ្ណោះ ។

- យល់ឃើញថា ការដែលដើមចោទអះអាងថា ក្រោយពីឪពុកខ្លួនស្លាប់ នៅឆ្នាំ១៩៨៨ ខ្លួនបានចូលទៅស្នាក់នៅបន្តសិទ្ធិ និង អាស្រ័យផលលើដីទំនាស់នោះគឺជាការ ពុំសមហេតុ សមផលទេ ពីព្រោះចម្លើយរបស់ខ្លួនក៏ដូចសាក្សីដែរ ឆ្លើយប្រឈូកប្រឈល់មិនច្បាស់ លាស់ទាំងពេលវេលា ទាំងទីតាំងដី ទាំងការអាស្រ័យផល ដែលសុទ្ធតែពុំមានភស្តុតាងច្បាស់លាស់ គួរអោយជឿបានទេឡើយ ។

យល់ឃើញថា ការដែល តុលាការ ថ្នាក់ក្រោម និង សាលាឧទ្ធរណ៍ សំរេច ប្រគល់ដីទំនាស់ទៅអោយដើមចោទ ដោយយកអំណះអំណាងថា ដើមចោទបានចូលមករស់នៅ លើដីទំនាស់តាំងពីឆ្នាំ១៩៨៣ តាមរយៈរដ្ឋអំណាច ភូមិ-ក្រុម និង អ្នកថែរក្សាដីនោះជាការ ភាន់ច្រឡំ ពីព្រោះ សាលាឧទ្ធរណ៍ និង តុលាការថ្នាក់ក្រោមពុំបានពិចារណាបន្ថែមអោយ បានច្បាស់លាស់ពីចម្លើយរបស់រដ្ឋអំណាចទាំងនោះ និង សាក្សីដែលបញ្ជាក់ថាការសុំរស់នៅនេះ នៅឆ្នាំ១៩៨៥ ក្នុងលក្ខណៈជាបណ្ដោះអាសន្នត្រឹមតែមួយជីវិតរបស់ខ្លួនតែប៉ុណ្ណោះ ។ ម៉្យាង ទៀត កាលសុំរស់នៅនោះឪពុកដើមចោទមានជំងឺផង ហើយរស់នៅតែម្នាក់ឯងប៉ុណ្ណោះ ។ ឯដើមចោទ និង ម្ដាយដើមចោទពេលនោះកំពុងរស់នៅឯផ្សារ មានផ្ទះត្រឹមត្រូវផង ។ ដូច្នេះដើមចោទដែលពុំធ្លាប់រស់នៅនោះ ពុំអាចឡើងជាម្ចាស់លើដីទំនាស់បានទេឡើយ ។

- យល់ឃើញថា តុលាការកំពូល បានចេញលិខិតបង្គាប់អោយដើមចោទធ្វើ សារណាតបរួចហើយ ប៉ុន្តែមានសេចក្ដីបញ្ជាក់ពីសមត្ថកិច្ចមូលដ្ឋានថា ឈ្មោះនេះចេញបាត់ ពីមូលដ្ឋានហើយ ។ តុលាការកំពូល បានចុះផ្សាយដំណឹងនេះតាមសារពត៌មានកម្ពុជាលេខ ១.១០៥ ចុះថ្ងៃទី ២៥-១១-៩៧ រួចហើយដែរ ក៏ប៉ុន្តែនៅតែពុំឃើញសាមីខ្លួនធ្វើសារណា ជូនមក តុលាការកំពូល ដដែល ហើយក៏ពុំបានមកចូលរួម សវនាការ នេះដែរ ដូច្នេះ - តុលាការកំពូល ជំនុំជំរះ រឿងនេះកំបាំងមុខដើមចោទប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាឧទ្ធរណ៍លេខ ៤៤៥ ចុះថ្ងៃទី ០៤-១១-៥៦ របស់ សាលាឧទ្ធរណ៍ ដែលបានសំរេចរឿងក្តីឧក្រិដ្ឋនេះមានការ ខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខអ្នកស្រី ទី សេង កំបាំងមុខអ្នកស្រី ពោធ ស៊ុនណារ៉ា ប៉ុន្តែ ចាត់ទុកជាចំពោះមុខ

១ - ទទួលបណ្តឹងសាទុក្ខលេខ ៣៤៧ ចុះថ្ងៃទី ០៤-១២-៥៦ របស់អ្នកស្រី ទី សេង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - ទុកជាមោឃៈ សាលដីកាឧទ្ធរណ៍លេខ ៤៤៥ ចុះថ្ងៃទី ០៤-១១-៥៦ របស់ សាលាឧទ្ធរណ៍ ទាំងមូល ។

៣ - បញ្ជូនសំណុំរឿងឧទ្ធរណ៍លេខ ៨៥ ចុះថ្ងៃទី ២០-៣-៥៧ របស់ តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បី ជំនុំជំរះ ជាថ្មីឡើងវិញ ។

៤ - ទីបះរូលប្រាក់ប្រយោជន៍ដែលអ្នកស្រី ទី សេង បានបង់ទុកនៅ តុលាការកំពូល ចំនួន ១៩.០០០ រៀល គឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធរឿងចំនួន ៤.០០០រ៛០០ ប៉ុន្តែប្រាក់នេះត្រូវកាត់ ចំនួន ៨០០រ៛០០ សំរាប់ជារង្វាន់ក្រឡាបញ្ជីការនិងប្រាក់
- ចំណាយក្នុងការប្រតិបត្តិការនោះចំនួន ១៥.០០០រ៛០០ សរុប ១៩.០០០រ៛០០

ដើម្បីត្រូវអោយអ្នកស្រី ពោធ ស៊ុនណារ៉ា សងប្រាក់ចំនួន ១៩.០០០រ៛០០ នេះទៅ អ្នកស្រី ទី សេង វិញ ។

៥ - សាលដីកានេះ ប្រកាស នាសវនាការ ជាសាធារណៈ នៅថ្ងៃទី ១៣ - ខែតុលា ឆ្នាំ១៩៥៨ ។